THE SCHOOL DISTRICT OF PHILADELPHIA

Division of Academic Services
Suite 210
440 North Broad Street
Philadelphia, PA 19130

ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០២៣

ជូនចំពោះ មាតាបិតា និងក្រុមគ្រួសារទាំងអស់របស់ ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា៖

របាយការណ៍ពិន្ទុបណ្តោះអាសន្នក្នុងរដូវរងាបានបញ្ចប់នៅថ្ងៃពុធ ទី ១ ខែ មីនា ឆ្នាំ ២០២៣។ រយៈពេលនៃរបាយការណ៍ពិន្ទុបណ្តោះអាសន្ននេះផ្តល់ពេលវេលាសម្រាប់ក្រុមគ្រួសារ និងសិស្សពិនិត្យមើលការរីកចម្រើនក្នុងការសិក្សាមុនពេលចេញរបាយការណ៍ពិន្ទុនៅចុងបញ្ចប់ត្រីមាស។ **របាយការណ៍ពិន្ទុបណ្តោះអាសន្នក៏ជាឱកាសដ៏ល្អដើម្បីពិនិត្យមើលការរីកចម្រើនរបស់កូនលោកអ្នកឆ្ពោះទៅកាន់ការបញ្ចប់ការសិក្សាផងដែរ។**

នេះគឺជាវិធីជាក់លាក់មួយចំនួនដើម្បីពិនិត្យមើលរបាយការណ៍ពិន្ទុបណ្តោះអាសន្នតាមរយៈនៃការយល់ឃើញទៅកាន់ការបញ្ចប់ការសិក្សា៖

1. ប្រើ បញ្ជីផ្ទៀងផ្ទាត់សម្រាប់ការបញ្ចប់ការសិក្សា នេះ ដើម្បីប្រាកដថារៀនបានតាមតម្រូវការ និង/ឬ កំពុងស្ថិតនៅក្នុងភាពដែលអាចរៀនបានតាមតម្រូវការ។
2. ពិនិត្យមើលការណែនាំតាមដំណាក់កាលក្នុងការចូលមើលស្ថានភាពបញ្ចប់ការសិក្សារបស់សិស្ស ដែលអាចឃើញ នៅទីនេះ ដើម្បីទាញយករបាយការណ៍ និងមើលព័ត៌មានលម្អិតអំពីការសិក្សារបស់កូនលោកអ្នក។
3. រាប់ក្រេឌីត។ ប្រសិនបើលោកអ្នកសម្គាល់ឃើញថាកូនរបស់លោកអ្នករៀនមិនបានតាមតម្រូវការ សូមណាត់ពេលប្រជុំជាមួយសាលារបស់ពួកគេដើម្បីពិភាក្សាអំពីផែនការ។
4. ត្រូវប្រាកដថា មុខវិជ្ជាសិក្សា និងកម្មវិធីរបស់កូនលោកអ្នក ត្រូវតាមផ្លូវទៅកាន់ការបញ្ចប់ការសិក្សាមួយ ក្នុងចំណោម ផ្លូវជាច្រើនទៅកាន់ការបញ្ចប់ការសិក្សា។ កែតម្រូវតាមការចាំបាច់ ដោយមានជំនួយពីគ្រូ និងអ្នកផ្តល់ឱវាទនៅសាលា។

**សូមចាំថា យើងជាដៃគូរបស់លោកអ្នកដើម្បីជោគជ័យរបស់កូនលោកអ្នក!** យើងនឹងធ្វើឱ្យប្រាកដថានឹងទំនាក់ទំនងជាមួយលោកអ្នកម្តងទៀត មុនពេលប្រជុំចែករបាយការណ៍ពិន្ទុ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២៩ ដល់ ៣១ ខែ មីនា ក្នុងឆ្នាំនេះ។ ប្រសិនបើលោកអ្នកមានសំណួរទូទៅ សូមទាក់ទង ក្រុមផ្លូវទៅកាន់ការបញ្ចប់ការសិក្សា តាមរយៈអ៊ីមែល gradreq@philasd.org ឬ 215-400-5536។ ព័ត៌មានបន្ថែម ប្រភពជំនួយ និងឱកាសចូលរួម មាននៅលើគេហទំព័រនៃការបញ្ចប់ការសិក្សារបស់ក្រសួងអប់រំ – www.philasd.org/graduate ។

សូមអរគុណចំពោះភាពជាដៃគូរបស់លោកអ្នក!

ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា
ផ្នែកផ្តល់ការបម្រើដល់ការសិក្សា